# សិទ្ធិ និងការការពាររបស់អ្នកទៅនឹងវិក្កយបត្រពេទ្យដែលមិនបានរំពឹងទុកមុន

Your Rights and Protections Against Surprise Medical Bills (Khmer)

នៅពេលអ្នកទទួលបានការថែទាំក្នុងភាពអាសន្ន ឬទទួលបានការព្យាបាលពីអ្នកផ្តល់សេវាក្រៅបណ្តាញនៅមន្ទីរពេទ្យក្នុងបណ្តាញ ឬមជ្ឈមណ្ឌលវះកាត់សង្គ្រោះបន្ទាន់ អ្នកទទួលបានការការពារពីការចេញវិក្កយបត្រសម្រាប់សមតុល្យនោះ។ នៅក្នុងករណីទាំងនេះ គេមិនគួរគិតថ្លៃអ្នកលើសពីការបង់ប្រាក់រួម ការធានារ៉ាប់រងរួម និង/ឬប្រាក់កាត់កងក្នុងគម្រោងរបស់អ្នកនោះទេ។

**តើ “ការចេញវិក្កយបត្រសម្រាប់សមតុល្យ” (ពេលខ្លះហៅថា “ការចេញវិក្កយបត្រដែលមិនបានរំពឹងទុកមុន”) ជាអ្វី?**

នៅពេលអ្នកទៅជួបគ្រូពេទ្យ ឬអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀត អ្នកអាចជំពាក់ថ្លៃចំណាយចេញពីហោប៉ៅជាក់លាក់ ដូចជាការបង់ប្រាក់រួម ការធានារ៉ាប់រងរួម ឬប្រាក់កាត់កងជាដើម។ អ្នកអាចមានថ្លៃចំណាយបន្ថែម ឬត្រូវបង់ថ្លៃវិក្កយបត្រទាំងស្រុង ប្រសិនបើអ្នកទៅជួបអ្នកផ្តល់សេវា ឬពិគ្រោះនៅមណ្ឌលថែទាំសុខភាពដែលមិនមាននៅក្នុងបណ្តាញនៃគម្រោងសុខភាពរបស់អ្នក។

“ក្រៅបណ្តាញ” មានន័យថា អ្នកផ្តល់សេវា និងមណ្ឌលថែទាំដែលមិនបានចុះកិច្ចសន្យាជាមួយគម្រោងសុខភាពរបស់អ្នកដើម្បីផ្តល់សេវា។ អ្នកផ្តល់សេវាក្រៅបណ្តាញអាចទទួលបានការអនុញ្ញាតឱ្យចេញវិក្កយបត្រដល់អ្នកសម្រាប់ចំនួនខុសគ្នារវាងអ្វីដែលគម្រោងរបស់អ្នកបង់ថ្លៃ និងចំនួនទឹកប្រាក់ពេញដែលបានគិតថ្លៃសម្រាប់សេវានោះ។ វាហៅថា “វិក្កយបត្រសម្រាប់សមតុល្យ”។ ចំនួនទឹកប្រាក់នេះទំនងជាច្រើនជាងថ្លៃចំណាយក្នុងបណ្តាញសម្រាប់សេវាកម្មដូចគ្នា ហើយប្រហែលជាមិនរាប់បញ្ចូលទៅក្នុងប្រាក់កាត់កង ឬដែនកំណត់ចេញពីហោប៉ៅប្រចាំឆ្នាំរបស់គម្រោងអ្នកទេ។

“ការចេញវិក្កយបត្រដែលមិនបានរំពឹងទុកមុន” ជាវិក្កយបត្រសម្រាប់សមតុល្យដែលមិនបានគិតទុកជាមុន។ វាអាចកើតឡើងនៅពេលអ្នកមិនអាចគ្រប់គ្រងអ្នកដែលពាក់ព័ន្ធក្នុងការថែទាំរបស់អ្នកបាន—ដូចជានៅពេលអ្នកស្ថិតក្នុងភាពអាសន្ន ឬនៅពេលអ្នកកំណត់ពេលជួបពិនិត្យនៅមជ្ឈមណ្ឌលក្នុងបណ្តាញ ប៉ុន្តែទទួលបានការព្យាបាលដោយមិនបានរំពឹកទុកពីអ្នកផ្តល់សេវាក្រៅបណ្តាញនោះ។ វិក្កយបត្រពេទ្យដែលមិនបានរំពឹងទុកមុនអាចមានតម្លៃរាប់ពាន់ដុល្លារអាស្រ័យលើនីតិវិធី ឬសេវាកម្មនោះ។

**អ្នកទទួលបានការការពារពីការចេញវិក្កយបត្រសម្រាប់សមតុល្យនោះចំពោះ៖**
**សេវាកម្មក្នុងភាពអាសន្ន**

ប្រសិនបើអ្នកមានស្ថានភាពសុខភាពក្នុងភាពអាសន្ន ហើយទទួលបានសេវាកម្មក្នុងភាពអាសន្នពីអ្នកផ្តល់សេវា ឬមណ្ឌលថែទាំក្រៅបណ្តាញនោះ ចំនួនច្រើនបំផុត ដែលពួកគេអាចចេញវិក្កយបត្រឱ្យអ្នកគឺស្មើនឹងចំនួនទឹកប្រាក់ចែករំលែកថ្លៃចំណាយក្នុងបណ្តាញរបស់គម្រោងអ្នក (ដូចជាការបង់ប្រាក់រួម ការធានារ៉ាប់រងរួម និងប្រាក់កាត់កង)។ អ្នកមិនអាចទទួលបានវិក្កយបត្រគិតថ្លៃសមតុល្យចំពោះសេវាកម្មក្នុងភាពអាសន្នទាំងនេះទេ។ វារាប់បញ្ចូលទាំងសេវាកម្ម ដែលអ្នកអាចទទួលបានក្រោយពីអ្នកស្ថិតក្នុងស្ថានភាពនឹងនរវិញ លុះត្រាតែអ្នកផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ និងបោះបង់ការការពាររបស់អ្នក កុំឱ្យចេញវិក្កយបត្រសម្រាប់សមតុល្យចំពោះសេវាកម្មក្រោយស្ថានភាពនឹងនរទាំងនេះ។

សូមមើលព័ត៌មានខាងក្រោមអំពីច្បាប់ស្តីពីការចេញវិក្កយបត្រសម្រាប់សមតុល្យរបស់រដ្ឋនៅក្នុងរដ្ឋ Arizona, Florida, Iowa, Minnesota និង Wisconsin។

**សេវាកម្មជាក់លាក់មួយចំនួននៅឯមន្ទីរពេទ្យ និងមជ្ឈមណ្ឌលវះកាត់សង្គ្រោះបន្ទាន់ក្នុងបណ្តាញ**

នៅពេលអ្នកទទួលបានសេវាកម្មពីមន្ទីរពេទ្យ និងមជ្ឈមណ្ឌលវះកាត់សង្គ្រោះបន្ទាន់ក្នុងបណ្តាញ អ្នកផ្តល់សេវាមួយចំនួននៅទីនោះអាចនៅក្រៅបណ្តាញ។ នៅក្នុងករណីទាំងនេះ ចំនួនច្រើនបំផុតដែលអ្នកផ្តល់សេវាទាំងនោះអាចចេញវិក្កយបត្រឱ្យអ្នកបានគឺស្មើនឹងចំនួនទឹកប្រាក់ចែករំលែកថ្លៃចំណាយក្នុងបណ្តាញរបស់គម្រោងអ្នក។ ករណីនេះអនុវត្តចំពោះថ្នាំសង្គ្រោះបន្ទាន់ ថ្នាំសន្លប់ រោគវិទ្យា វិទ្យុសកម្ម មន្ទីរពិសោធន៍ ឯកទេសជំងឺទារក ជំនួយការគ្រូពេទ្យវះកាត់ គ្រូពេទ្យក្នុងមន្ទីរពេទ្យ ឬសេវារបស់គ្រូពេទ្យថែទាំជំងឺធ្ងន់ធ្ងរ។ អ្នកផ្តល់សេវាទាំងនេះមិនអាចចេញវិក្កយបត្រសម្រាប់សមតុល្យឱ្យអ្នកបានទេ ហើយមិនអាចសុំឱ្យអ្នកបោះបង់ការការពាររបស់អ្នក កុំឱ្យចេញវិក្កយបត្រសម្រាប់សមតុល្យនោះទេ។ ប្រសិនបើអ្នកទទួលបានប្រភេទសេវាកម្មផ្សេងទៀតនៅឯមណ្ឌលថែទាំក្នុងបណ្តាញទាំងនេះ អ្នកផ្តល់សេវាក្រៅបណ្តាញមិនអាចចេញវិក្កយបត្រសម្រាប់សមតុល្យឱ្យអ្នកបានទេ លុះត្រាតែអ្នកផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ និងបោះបង់ការការពាររបស់អ្នក។

**<u>មិនដែល</u>តម្រូវឱ្យអ្នកបោះបង់ការការពាររបស់អ្នកពីការចេញវិក្កយបត្រសម្រាប់សមតុល្យនោះឡើយ។ ក៏មិនតម្រូវឱ្យអ្នកទទួលការថែទាំក្រៅបណ្តាញនោះដែរ។ អ្នកអាចជ្រើសរើសអ្នកផ្តល់សេវា និងមណ្ឌលថែទាំក្នុងបណ្តាញរបស់គម្រោងអ្នកបាន។**

សូមមើលព័ត៌មានខាងក្រោមអំពីច្បាប់ស្តីពីការចេញវិក្កយបត្រសម្រាប់សមតុល្យរបស់រដ្ឋនៅក្នុងរដ្ឋ Arizona, Florida, Iowa, Minnesota និង Wisconsin។

**នៅពេលដែលមិនអនុញ្ញាតឱ្យចេញវិក្កយបត្រសម្រាប់សមតុល្យ អ្នកក៏មានការការពារទាំងនេះផងដែរ៖**

- អ្នកទទួលខុសត្រូវតែសម្រាប់ការបង់លើការចែករំលែកថ្លៃចំណាយរបស់អ្នកប៉ុណ្ណោះ (ដូចជាការបង់ប្រាក់រួម ការធានារ៉ាប់រងរួម និងប្រាក់កាត់កង ដែលអ្នកនឹងបង់ថ្លៃ ប្រសិនបើអ្នកផ្តល់សេវា ឬមណ្ឌលថែទាំនោះស្ថិតនៅក្នុងបណ្តាញ)។ គម្រោងសុខភាពរបស់អ្នកនឹងបង់ថ្លៃបន្ថែមណាមួយដល់អ្នកផ្តល់សេវា និងមណ្ឌលថែទាំក្រៅបណ្តាញដោយផ្ទាល់។
- ជាទូទៅ គម្រោងសុខភាពរបស់អ្នកត្រូវតែ៖
  - ធានារ៉ាប់រងលើសេវាកម្មក្នុងភាពអាសន្នដោយមិនតម្រូវឱ្យអ្នកទទួលបានការយល់ព្រមសម្រាប់សេវាកម្មជាមុនទេ (ដែលគេស្គាល់ថាជា “ការអនុញ្ញាតជាមុន”)។
  - ធានារ៉ាប់រងលើសេវាក្នុងភាពអាសន្នដោយអ្នកផ្តល់សេវាក្រៅបណ្តាញ។
  - ផ្អែកលើអ្វីដែលអ្នកជំពាក់អ្នកផ្តល់សេវា ឬមណ្ឌលថែទាំ (ការចែករំលែកថ្លៃចំណាយ) លើអ្វីដែលគម្រោងនឹងបង់ថ្លៃឱ្យអ្នកផ្តល់សេវា ឬមណ្ឌលថែទាំក្នុងបណ្តាញ និងបង្ហាញចំនួនទឹកប្រាក់នោះនៅក្នុងការពន្យល់អំពីអត្ថប្រយោជន៍របស់អ្នក។
  - រាប់បញ្ចូលចំនួនទឹកប្រាក់ណាមួយដែលអ្នកបានបង់សម្រាប់សេវាកម្មក្នុងភាពអាសន្ន ឬសេវាកម្មក្រៅបណ្តាញទៅក្នុងប្រាក់កាត់កង និងដែនកំណត់ប្រាក់ចេញពីហោប៉ៅក្នុងបណ្តាញរបស់អ្នក។



MC5815-57KMrev0424

អាស្រ័យលើទីតាំងដែលអ្នកបានទៅជួបពិនិត្យ ច្បាប់របស់រដ្ឋនៅក្នុងរដ្ឋ Arizona, Florida, Iowa, Minnesota ឬ Wisconsin អាចផ្តល់ការការពារចំពោះការចេញវិក្កយបត្រសម្រាប់សមតុល្យបន្ថែមបាន។ ប៉ុន្តែ ការការពារទាំងនេះអនុវត្តចំពោះតែគម្រោងសុខភាពដែលស្ថិតនៅក្រោមច្បាប់របស់រដ្ឋប៉ុណ្ណោះ។ សូមមើលព័ត៌មានបន្ថែមខាងក្រោមអំពីច្បាប់រដ្ឋទាំងនេះ៖

- ច្បាប់រដ្ឋ **Arizona** ការពារទៅនឹងការចេញវិក្កយបត្រសម្រាប់សមតុល្យចំពោះសេវាកម្មក្នុងភាពអាសន្ន និងមិននៅក្នុងភាពអាសន្នជាក់លាក់នៅក្រៅបណ្តាញ បន្ថែមពីលើដំណើរការដោះស្រាយជម្លោះរបស់អ្នកប្រើប្រាស់។ សូមមើលច្បាប់ដែលបានកែសម្រួលរបស់រដ្ឋ Arizona §§ 20-3111-3119 និងចូលមើលគេហទំព័រ https://difi.az.gov/soonbdr។
- ច្បាប់រដ្ឋ **Florida** ការពារទៅនឹងការចេញវិក្កយបត្រសម្រាប់សមតុល្យចំពោះសេវាកម្មក្នុងភាពអាសន្ន និងសេវាកម្មដែលមិននៅក្នុងភាពអាសន្នជាក់លាក់នៅក្រៅបណ្តាញ។ រដ្ឋ Florida ក៏ផ្តល់នូវដំណើរការដោះស្រាយជម្លោះរបស់អ្នកប្រើប្រាស់សម្រាប់ជម្លោះមួយចំនួនផងដែរ។ សូមមើលច្បាប់របស់រដ្ឋ Florida §§ 627.64194, 641.3154, 641.513 និង 408.7057។
- ច្បាប់រដ្ឋ **Iowa** ការពារទៅនឹងការចេញវិក្កយបត្រសម្រាប់សមតុល្យចំពោះសេវាកម្មក្នុងភាពអាសន្ននៅក្រៅបណ្តាញ។ សូមមើលក្រមច្បាប់របស់រដ្ឋ Iowa § 514C.16។
- ច្បាប់រដ្ឋ **Minnesota** ការពារទៅនឹងការចេញវិក្កយបត្រសម្រាប់សមតុល្យចំពោះសេវាកម្មក្នុងភាពអាសន្ន និងមិននៅក្នុងភាពអាសន្នជាក់លាក់។ សូមមើលច្បាប់របស់រដ្ឋ Minnesota §§ 62K.11, 62Q.55 និង 62Q.556។
- រដ្ឋ **Wisconsin** មិនមានការការពារលើការចេញវិក្កយបត្រសម្រាប់សមតុល្យនៅក្រោមច្បាប់រដ្ឋបច្ចុប្បន្ននេះទេ។

**ប្រសិនបើអ្នកជឿថា អ្នកបានទទួលវិក្កយបត្រមិនត្រឹមត្រូវ៖**

សូមចូលមើលមជ្ឈមណ្ឌលសម្រាប់សេវា Medicare និង Medicaid (CMS) តាមរយៈគេហទំព័រ cms.gov/nosurprises/consumers សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកក្រោមច្បាប់សហព័ន្ធ។ អ្នកក៏អាចទាក់ទងទៅកាន់ផ្នែកជំនួយចំពោះវិក្កយបត្រមិនបានរំពឹងទុកមុន (No Surprises Helpdesk) ដោយការហៅទូរសព្ទទៅលេខ 1-800-985-3059។

សូមចូលមើលគេហទំព័រខាងក្រោមសម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកក្រោមច្បាប់រដ្ឋដែលអាចអនុវត្តបាន៖

- រដ្ឋ Arizona៖ https://difi.az.gov/soonbdr
- រដ្ឋ Florida៖ https://www.floir.com/, https://myfloridacfo.com/Division/Consumers/
- រដ្ឋ Iowa៖ https://iid.iowa.gov/legal-resources/legal-information/no-surprises-act/no-surprises-act-consumer-information
- រដ្ឋ Minnesota៖ https://www.ag.state.mn.us/consumer/health/default.asp
- រដ្ឋ Wisconsin៖ https://oci.wi.gov/Pages/Consumers/Health.aspx